# LONG BEACH Utilities
Water · Gas · Sewer

# កម្មវិធីបញ្ចុះតម្លៃឧស្ម័នសម្រាប់អ្នកដែលមានចំណូលទាប

## តើវាគឺជាអ្វី?

យូធីលីធីឡុងប៊ិច (Long Beach Utilities) នៅទីនេះដើម្បីជួយគ្រួសារដែលត្រូវការជំនួយ។ អតិថិជនលំនៅដ្ឋានដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចដាក់ពាក្យស្នើសុំកម្មវិធីបញ្ចុះតម្លៃឧស្ម័នសម្រាប់អ្នកដែលមានប្រាក់ចំណូលទាប ដើម្បីទទួលបានការបញ្ចុះតម្លៃ 20 ភាគរយលើវិក្កយបត្រឧស្ម័នធម្មជាតិប្រចាំខែរបស់ពួកគេ។ ការបញ្ចុះតម្លៃនឹងត្រូវចូលជាធរមានចំពោះគណនីរបស់អ្នកភ្លាមៗ នៅពេលដែលកម្មវិធីត្រូវបានដំណើរការ និងអនុម័តដោយយូធីលីធីឡុងប៊ិច។

**សំណួរ? ទូរស័ព្ទមកយើង លេខ(562) 570-2068 ។.**

## របៀបដែលអាចទទួលបាន

**លក្ខខណ្ឌនៃការចូលរួម (ប្រជាពលរដ្ឋ)៖**

- វិក្កយបត្រសេវាយូធីលីធីក្រុងរបស់អ្នក ត្រូវតែជាឈ្មោះរបស់អ្នក ហើយត្រូវតែជាអាស័យដ្ឋានចម្បងរបស់អ្នក
- អ្នកមិនត្រូវអះអាងថាជាអ្នកពឹងអាស្រ័យកលើការបង់ពន្ធរបស់អ្នកដ៏ទៃឡើយ ក្រៅពីប្ដី ឬប្រពន្ធរបស់អ្នក
- ប្រាក់ចំណូលគ្រួសារប្រចាំឆ្នាំរបស់អ្នក មិនលើសពីតម្លៃដែលមានចែងក្នុងតារាងខាងក្រោម

**លក្ខខណ្ឌក្នុងការចូលរួម (ទីកន្លែងស្នាក់នៅជាក្រុម ដែលមិនស្វែងរកប្រាក់ចំណេញ)៖**

- ទីកន្លែងត្រូវតែមានម៉ែត្រឧស្ម័នដាច់ដោយឡែក
- ប្រជាពលរដ្ឋនៅទីកន្លែងនោះ ត្រូវតែបំពេញតាមកម្រិតនៃតម្រូវការប្រាក់ចំណូលគ្រួសារសម្រាប់ឬដូចទៅនឹងគ្រួសារដែលមានមនុស្សតែម្នាក់
- 70 ភាគរយនៃឧស្ម័នធម្មជាតិដែលត្រូវបានប្រើប្រាស់នៅក្នុងទីកន្លែងនោះ ត្រូវតែប្រើសម្រាប់គោលបំណងលំនៅដ្ឋាន
- ទីកន្លែងនោះត្រូវតែផ្តល់ទម្រង់ 501 (c)(3) ថ្មីបំផុត, អាជ្ញាប័ណ្ណលំនៅដ្ឋានសម្រាប់មនុស្សពេញវ័យរបស់រដ្ឋកាលីហ្វ័រញ៉ា បច្ចុប្បន្ន ឬលិខិតអនុញ្ញាតប្រើប្រាស់តាមលក្ខខណ្ឌសម្រាប់ជម្រកដល់ជនអនាថាឬជនគ្មានផ្ទះសម្បែង

**តម្រូវការនៃប្រាក់ចំណូល:**

| ប្រាក់ចំណូលគ្រួសារអតិបរមា | |
|---|---|
| # មនុស្សក្នុងគ្រួសារ | ចំណូលប្រចាំឆ្នាំ |
| 1-2 | $36,620 |
| 3 | $46,060 |
| 4 | $55,500 |
| 5 | $64,940 |
| Each additional person | $9,440 |

*អត្រាជំនួសរបស់រដ្ឋកាលីហ្វ័រញ៉ាសម្រាប់តម្រូវការប្រាក់ចំណូលនៃកម្មវិធីថាមពល

**អ្នកក៏អាចមានលក្ខណៈគ្រប់គ្រាន់ផងដែរ ប្រសិនបើអ្នក ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកចូលរួមក្នុងកម្មវិធីណាមួយទាំងនេះ៖**

- Medicaid or Medi-Cal
- CalFresh/SNAP (food stamps)
- Healthy Families A&B
- CalWORKS
- Women, Infants & Children (WIC)
- National School Lunch Program (NSLP)
- Low Income Home Energy Assistance Program (LIHEAP)
- Supplemental Security Income (SSI)
- Tribal TANF
- Head Start Income Eligible (Tribal only)
- Bureau of Indian Affairs General Assistance

## ជំនួយបន្ថែម

- **កម្មវិធីជំនួយថាមពលដល់លំនៅដ្ឋានដែលមានប្រាក់ចំណូលទាប៖** ផ្តល់ជំនួយក្នុងការទូទាត់វិក្កយបត្រ, ជំនួយវិក្កយបត្របន្ទាន់, និងសេវាកម្មអាកាសធាតុ។ ដើម្បីសាកសួរ សូមទូរស័ព្ទទៅកាន់ Long Beach Community Action Partnership (LBCAP) តាមរយៈលេខ (888) 351-4061។
- **មូលដ្ឋានវេជ្ជសាស្ត្រ:** អ្នកដែលមានលក្ខខណ្ឌវេជ្ជសាស្ត្រមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចទទួលបានប្រាក់ឧបត្ថម្ភចំពោះការបន្ថែមនៃឧស្ម័នដែលបន្ទាបអត្រាតម្លៃទៅកម្រិតទី 1។ គ្រូពេទ្យត្រូវតែបញ្ជាក់អំពីស្ថានភាពសុខភាព។ ដើម្បីសាកសួរ សូមទូរស័ព្ទទៅកាន់សេវាយូធីលីធីតាមលេខ (562) 570-5700 ។

## ឯកសារចាំបាច់នានា

សូមត្រៀមខ្លួនដើម្បីដាក់ឯកសារដូចខាងក្រោមនេះអមជាមួយនឹងពាក្យសុំរបស់អ្នក៖

- ភស្តុតាងនៃប្រាក់ចំណូល ដូចជា W-2 ឬលិខិតអត្ថប្រយោជន៍សន្តិសុខសង្គម ថ្មីបំផុតរបស់អ្នក
- ភស្តុតាងនៃការចូលរួមក្នុងកម្មវិធីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានរាយខាងលើ។

## របៀបដាក់ពាក្យសុំ

សូមបំពេញ និងចុះហត្ថលេខាលើពាក្យសុំនៅទំព័របន្ទាប់ ហើយផ្ញើអ៊ីមែលទៅ billing@lbutilities.org ឬផ្ញើទៅកាន់៖

Long Beach Utilities Billing
2400 E. Spring St.
Long Beach, CA 90806

អ្នកក៏អាចបំពេញពាក្យសុំនេះ តាមគេហទំព័រ lbwater.org/billhelp។

# កម្មវិធីបញ្ចុះតម្លៃឧស្ម័នសម្រាប់អ្នកដែលមានចំណូលទាប

## លេខដាក់ពាក្យសុំ

**លេខគណនីយូធីលីធី:** ____________________________________________

**ប្រភេទគណនី:** _____ លំនៅដ្ឋាន _____ ទីកន្លែងក្រុមមិនរកប្រាក់ចំណេញ

**ឈ្មោះអតិថិជន:** ____________________________________________

**អាសយដ្ឋានសេវាកម្ម:** ____________________________________________

____________________________________________

**ទូរស័ព្ទ:** ______________________ **អ៊ីម៉ែល:** ______________________

**មនុស្សពេញវ័យ, កុមារក្នុងគ្រួសារ:** __________ **ប្រាក់ចំណូលគ្រួសារ:** ______________

**តើអ្នក ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកបានចុះឈ្មោះក្នុងកម្មវិធីណាមួយដែលបានរាយខាងលើ?**
បាទចាស / ទេ

**សូមបញ្ជាក់អោយច្បាស់:** ____________________________________________

ខ្ញុំប្រកាសថាព័ត៌មានដែលខ្ញុំបានផ្តល់នៅក្នុងពាក្យសុំនេះគឺពិតប្រាកដ និងត្រឹមត្រូវ។
ខ្ញុំយល់ព្រមផ្តល់ភស្តុតាងបន្ថែមអំពីលក្ខណៈសម្បត្តិ ប្រសិនបើមានការស្នើសុំ។
ខ្ញុំយល់ព្រមជូនដំណឹងដល់នាយកដ្ឋានទឹកឧស្ម័នរបស់ក្រុងឡុងប៊ិច
ប្រសិនបើខ្ញុំមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានការបញ្ចុះតម្លៃនេះទៀតទេ។

**ហត្ថលេខា:** ______________________________ **កាលបរិច្ឆេទ:** ______________